ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ...១១៦៤...អបក

រាជធានីភ្នំពេញ, ថ្ងៃទី ...១៦... ខែ ...[illegible]... ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការអនុវត្តការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី

***

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី
- យោងតាមការចាំបាច់ របស់ក្រសួងសុខាភិបាល៕



ទីស្តីការក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨២៦ ០៣៤ / ៨២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

## សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់គំរូ និងទំហំនៃសារព្រមានសុខភាពលើកញ្ចប់បារីដែលផលិតក្នុងស្រុក ឬនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ២.-

សារព្រមានសុខភាពមាន៥ប្រភេទដូចមានចែងក្នុងឧបសម្ព័ន្ធ ។ឧបសម្ព័ន្ធនេះអាចត្រូវបានកែប្រែយោងទៅតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

ប្រការ៣.-

សារព្រមានសុខភាពលើកញ្ចប់បារីត្រូវមានទំហំយ៉ាងតិច៣០ភាគរយលើផ្ទៃសំខាន់ ហើយត្រូវស្ថិតនៅផ្នែកខាងក្រោមនៃកញ្ចប់បារី ។

ប្រការ៤.-

ក. សារព្រមានសុខភាព ត្រូវបោះពុម្ពជាអក្សរពណ៌ខ្មៅ នៅលើផ្ទៃពណ៌ស នៃកញ្ចប់បារី ហើយត្រូវមានស៊ុមពណ៌ខ្មៅព័ទ្ធជុំវិញ ដែលមានកម្រាស់៥.៨៨ភាគរយ នៃប្រវែងទទឹងប្រអប់សារ ។

ខ. ចំពោះកញ្ចប់បារី សារព្រមានសុខភាពត្រូវប្រើពុម្ពអក្សរ លីម៉ូនអេស៤ និងការកំណត់ទំហំត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងឧបសម្ព័ន្ធ ។

ប្រការ៥.-

សារព្រមានសុខភាពទីមួយៗក្នុងចំណោមសារព្រមានសុខភាពទាំង៥ដែលមានចែងនៅក្នុងឧបសម្ព័ន្ធត្រូវបោះពុម្ពនៅលើសំបកកញ្ចប់បារីដោយធានាឱ្យសារព្រមានសុខភាពទាំង៥មានបោះពុម្ពបង្ហាញនៅលើកញ្ចប់បារីគ្រប់ប្រភេទទាំងអស់ ក្នុងបរិមាណស្មើគ្នា ក្នុងពេលតែមួយ ។

ប្រការ៦.-

ផលិតករក្នុងស្រុក និងអ្នកនាំចូលសម្រាប់ធ្វើការអ្នកចែកចាយនិងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរំលោភបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងនៅក្នុងមាត្រា៩ នៃអនុក្រឹត្យ លេខ១៨១អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី ។៚

ប្រការ៧.-

ប្រកាសឬសេចក្តីសម្រេចណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៨.-

ខុទ្ទការល័យ អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់អង្គភាពសុខាភិបាលថ្នាក់កណ្តាល រាជធានី ខេត្តត្រូវអនុវត្ត តាមប្រកាសនេះចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។៚

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងនិងស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ

ម៉ម-ប៊ុនហេង